ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ០០១ រ.បក/អររប

នាយកដ្ឋានបណ្ដុះបណ្ដាល
ចូល លេខ ០៧៤ ម៉ោង ១១:០០
ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៨
បញ្ជូន............

ថ្ងៃពុធ ៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៨

# របាយការណ៍
## ស្ដីពី
## សកម្មភាព និងលទ្ធផលការងារប្រចាំខែមករា និងទិសដៅការងារបន្តសម្រាប់ខែកុម្ភៈ ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង ១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

នៅក្នុងខែមករា ឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-<u>សកម្មភាពការងារ និងលទ្ធផល</u>

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារដែលបញ្ជូនមកពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះក្រសួងមហាផ្ទៃសរុបចំនួន **១២៤០ច្បាប់** និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន ៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **៥៤៣ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **៤៤ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៣១៧ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន **៤៨ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **៩៣ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន **១៩៥ច្បាប់**។

-បានចាត់ចែងបញ្ជូនឯកសារចំនួន **៥១៤ច្បាប់** ដែលក្នុងនោះ ឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន**២៤៦ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **២៣ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **១១៥ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន **២៧ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **៣៤ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន **៦៩ច្បាប់** ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យ សម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន **៣៨២ច្បាប់** ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍ និងពិនិត្យ សម្រេច ដែលក្នុងនោះ ឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **១៨៨ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **១៥ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៩៨ច្បាប់** នាយកដ្ឋានបណ្ដុះបណ្ដាលចំនួន **០៧ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **១៦ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន**៥៨ច្បាប់**។

-បានទទួលឯកសារចំនួន **២៧៤ច្បាប់** ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ បានពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន **១៦៨ច្បាប់** នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន **១២ច្បាប់** នាយកដ្ឋានបុគ្គលិកចំនួន **៥៦ច្បាប់** នាយកដ្ឋានបណ្តុះបណ្តាលចំនួន **០៥ច្បាប់** នាយកដ្ឋានមុខងារ និងធនធានចំនួន **១៣ច្បាប់** និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន **២០ច្បាប់**។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន **៣៨៧ច្បាប់** ក្នុងនោះលិខិតបង្គាប់ការចំនួន**១៧៨ច្បាប់** និងលិខិតបញ្ជាបេសកកម្មចំនួន **២០៩ច្បាប់** ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា។ ជាមួយគ្នានោះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្តដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

**ក្នុងខែមករា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ជាវាគ្មិន វេទិកា និងកម្មវិធីនានាដូចខាងក្រោម៖**

▪ ចូលរួមជាមួយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងឱកាសអនុញ្ញាតឱ្យ**

-ឯកឧត្តម **Takihiro Nakamura** អភិបាលនៃខេត្ត **Ehime** ប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-ឯកឧត្តម **KAZUYUKI NAKANE** អនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ចូលជួបសម្តែងការគួរសម។

▪ **ការប្រជុំ និងសិក្ខាសាលា៖**

- ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារសិក្សាស្រាវជ្រាវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- ចូលរួមក្នុងកិច្ចប្រជុំស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ និងមន្ត្រីនគរបាលជាតិ

- ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨

-ចូលរួមក្នុងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅទីក្រុងវៀងច័ន្ទ

-ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការកំណែវិញ្ញាសា និងអនុគណៈកម្មការនានា ដើម្បីធ្វើកំណែវិញ្ញាសាប្រឡងជ្រើសរើសសិស្ស-និស្សិត បញ្ចូលក្នុងក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៧

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងចុះហត្ថលេខា លើផែនការសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា អំពីតម្រូវការមុខវិជ្ជាសម្រាប់បណ្តុះបណ្តាលមន្ត្រីវគ្គខ្លី(០៣ខែ) នៅសាលាភូមិន្ទរដ្ឋបាល

- ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំសិក្ខាសាលាស្តីពីការពង្រឹងភាពអង់អាចនិងបណ្តាញក្រុមប្រឹក្សាជាស្ត្រីថ្នាក់ក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស

-ចូលរួមក្នុងកិច្ចប្រជុំរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ របស់អគ្គនាយករដ្ឋបាល ពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៨ របស់ គ.ជ.អ.ប

- ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈនៃបេឡាជាតិរបបសន្តិសុខសង្គមលើកទី១៣ និងទី១៤ ដើម្បីរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទាន របៀបបទ និងនីតិវិធី នៃការបង់ភាគទាន

របបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន ដែលរៀបចំដោយបេឡាជាតិរបបសន្តិសុខសង្គម

-រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ លើសេចក្តីព្រាងសៀវភៅណែនាំស្តីពីការរៀបចំ និងនីតិវិធីផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-ចូលរួមក្នុងកិច្ចប្រជុំរាយការណ៍ស្តីពីការវិភាគមុខងារ ការកំណត់ក្របខ័ណ្ឌ វឌ្ឍនភាពការងារ និងបញ្ហាប្រឈម របស់លេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ

-ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារស្តីពី សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា-ឡាវ-វៀតណាមដល់ឆ្នាំ២០៣០ នៅក្រសួងពាណិជ្ជកម្ម

-ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សា លើបច្ចេកទេសប្លង់ស្ថាបត្យកម្ម និងបញ្ជីវាយតម្លៃប៉ាន់ស្មានរបស់គម្រោងវិនិយោគសាងសង់ស្ពានសម្រាប់អ្នកដំណើរថ្មើរជើង(Skywalk)ចំនួន ០២កន្លែង នៅរដ្ឋបាលខេត្តកំពង់ស្ពឺ

-ចូលរួមក្នុងកិច្ចប្រជុំស្តីពីការពិនិត្យ លើសេចក្តីព្រាងលើកទី២គោលនយោបាយជាតិ ស្តីពីការសិក្សាពេញមួយជីវិត

-ចូលរួមក្នុងកិច្ចប្រជុំស្តីអំពីប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់ប្រើប្រាស់សាកល្បងនៅការិយាល័យច្រកចេញចូលតែមួយក្រុងបាត់ដំបង និងស្រុកមោងឫស្សី

-ចូលរួម និងរៀបចំកិច្ចប្រជុំណែនាំអំពីការនាំវិញ្ញាសាទៅកាន់មណ្ឌលប្រឡង និងនីតិវិធីសម្រាប់ការត្រួតពិនិត្យ ដំណើរការរៀបចំការប្រឡងជ្រើសរើសសិស្ស-និសិត្ស បញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសម្រាប់ឆ្នាំ២០១៧

-ចូលរួម និងរៀបចំកិច្ចប្រជុំបូកសរុបសមិទ្ធផលគម្រោងលើកកម្ពស់សេវាសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិរយៈពេល៦ឆ្នាំ

-បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយតំណាង UNICEF ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានរៀបចំកិច្ចប្រជុំជាមួយរាជធានី-ខេត្តលើ០២ប្រធានបទគឺ ប្រធានបទទី១៖ស្តីពីការរៀបចំប្រកាសចូលកាន់មុខដំណែងប្រធានក្រុមប្រឹក្សា មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ជំនួសដំណែងទំនេរផ្អែកតាមប្រកាសរបស់ក្រសួងមហាផ្ទៃ និងប្រធានបទទី២៖ស្តីពីការប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមបេបកំណត់០២ឆ្នាំ សម្រាប់ឆ្នាំ២០១៨ របស់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ទីប្រឹក្សា ជំនួយការ និងមន្ត្រីសាធារណៈទទួលអាណត្តិ ដោយការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ចូលរួមស្តាប់របាយការណ៍លទ្ធផលប្រជុំក្រុមការងារដោះស្រាយបញ្ហាបុរី៩៩៩ ស្តីពីការពិភាក្សាលើទិដ្ឋភាពច្បាប់ និងលទ្ធភាពក្នុងការចេញលិខិតសាងសង់ និងការបំបែកកម្មសិទ្ធិជូនអតិថិជនដែលបានទិញលំនៅឋានពីបុរី៩៩៩ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួងស្តីពីសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៧ស្តីពីលទ្ធផលអនុវត្តផែនការសកម្មភាព ២០១៦-២០១៨ នៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។

-ចូលរួមស្តាប់របាយការណ៍លទ្ធផលប្រជុំ គណៈកម្មការបច្ចេកទេសជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ នៅក្រសួងផែនការ

-ចូលរួមស្តាប់របាយការណ៍លទ្ធផលសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងស្តង់ដារ នីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដែលទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ នៅសណ្ឋាគារ Raffles Hotel Le Royal ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមស្តាប់របាយការណ៍លទ្ធផលក្នុងសិក្ខាសាលផ្សព្វផ្សាយគោលនយោបាយស្តីពីការលើកទឹកចិត្តនិងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រស្វែងរកការគាំទ្រយៃនឌ័រ របស់សមាគមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ នៅសណ្ឋាគារសុខាភ្នំពេញ

-ចូលរួមសិក្ខាសាលពិគ្រោះយោបល់ ស្តីពីទេសន្តរប្រវេសន៍ និងផលប៉ះពាល់លើក្រុមគ្រួសារ ដែលមិនបានធ្វើទេសន្តរប្រវេសន៍ទៅជាមួយ រៀបចំដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ នៅសណ្ឋាគារសាន់វេ

-បានធ្វើរបាយការណ៍លទ្ធផលចូលរួមប្រជុំប្រចាំឆ្នាំក្រុមប្រឹក្សាដៃគូទឹកកម្ពុជាឆ្នាំ២០១៧ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ នៅសណ្ឋាគារភ្ញៀប្រុសទីរួមខេត្តកំពង់ចាម ដែលរៀបចំដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

-បានធ្វើរបាយការណ៍លទ្ធផលស្តីពី ការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍ របស់រដ្ឋបាលរាជធានី ខណ្ឌ និងខេត្តបញ្ចប់ឆ្នាំ២០១៦ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី០៧ខែកក្កដា ឆ្នាំ២០១៧។

- **កម្មវិធីផ្សេងៗ៖**

-ចូលរួមក្នុងពិធីប្រកាសតែងតាំងមុខតំណែង ផ្ទេរភារកិច្ចអភិបាល នៃគណៈអភិបាលខេត្តកំពត និងអភិបាលអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ ខេត្តកំពងធំ និងខេត្តសៀមរាប។

- ចូលរួមក្នុងពិធីប្រកាសតែងតាំងមុខតំណែង ផ្ទេរភារកិច្ច បញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិ ព្រមទាំងបំពាក់ឋានន្តរស័ក្តិ ជូនដល់នាយនគរបាលជាតិជាន់ខ្ពស់ និងមន្ត្រីនគរបាល នៃអគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង។

-ចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តសៀមរាប កំពង់ឆ្នាំង កំពង់ស្ពឺ ស្វាយរៀង ប៉ៃលិន កោះកុង និងខេត្តស្ទឹងត្រែង។

-ចូលរួមសន្និបាតបូកសរុបវឌ្ឍភាព នៃការងារអត្តសញ្ញាណកម្មរយៈពេល ០៣ឆ្នាំ (២០១៤-២០១៧) និងលើកទិសដៅអនុវត្តបន្ត។

-ចូលរួមក្នុងកម្មវិធីមិទ្ទិងអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩នៃទិវាជ័យជំនះ៧មករា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ។

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ " **អគារសម្តេចក្រឡាហោម ស ខេង និងលោ[illegible] ជំទាវញ៉ែម សាខន** " នៅបណ្ឌិតសភានគរបាលកម្ពុជា។

-ចូលរួមពិធីសម្ពោធពិព័រណ៍ផលិតផលនាំចេញ-នាំចូលនិងខេត្ត១ផលិតផល១កម្ពុជាលើកទី១២នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។

-ចូលរួមវេទិកា ស្តីពីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ។

-ចូលរួមពិធីបិទវគ្គ និងចែកវិញ្ញាបនបត្រគ្រូបង្គោលជំនាន់ទី១ ជំនាញអភិបាលកិច្ចរបស់គម្រោងសាលាអភិបាលកិច្ច។

-ចូលរួមទស្សនាពិព័រណ៍សមិទ្ធផល នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ចូលរួមវេទិកាសាធារណៈក្រោមប្រធានបទស្តីពី "កិច្ចសហប្រតិបត្តិការ Lancang-Mekong ការកសាងសន្តិភាព និងភាពរុងរឿងសម្រាប់មហាអនុតំបន់ទន្លេមេគង្គ" កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ។

-បានចុះបណ្តុះបណ្តាលអំពីការរៀបចំកម្មវិធីគ្រប់គ្រងប័ណ្ណព្រំដែនកម្ពុជា-ថៃនិងកម្ពុជា-ឡាវ និងផ្តល់ប័ណ្ណព្រំដែនជូនខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ(ខេត្តពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្ត ព្រះវិហារ)និងខេត្តជាប់ព្រំដែនប្រទេសឡាវ (ខេត្តស្ទឹងត្រែង)។

-ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ។

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "វិធីសាស្ត្របែបចូលរួម" ចាប់ពីថ្ងៃទី២០ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ។

## ៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

### ៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង ដែលកំពុងរៀបចំ

- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសស្តីពី ការកំណត់គោលការណ៍ នៃការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការ នៅទីស្តីការក្រសួងមហាផ្ទៃ និងមន្ត្រីរាជការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- សេចក្តីព្រាងប្រកាស ស្តីពីការបង្កើតទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិក្នុងរចនាសម្ព័ន្ធសាលាខេត្តព្រះសីហនុ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី បែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

- សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធី និងរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅទីស្តីការក្រសួងមហាផ្ទៃ និង នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅកិច្ចការរដ្ឋបាលសម្រាប់ប្រើប្រាស់នៅតាមអង្គភាព(ផ្នែករដ្ឋបាលស៊ីវិល)ចំណុះទីស្តីការក្រសួងមហាផ្ទៃ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

### ៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

#### ៤.២.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន

-អនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

#### ៤.២.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងសហការរៀបចំ

- សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលការគណនារបបសោធននិវត្តន៍ជន និងជនបាត់បង់សមត្ថភាពការងារចំពោះយោធិន និងមន្ត្រីនគរបាលជាតិ

- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាល ក្រុង ស្រុក ខណ្ឌ

- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន

- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម

- សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម

- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- សេចក្តីព្រាង សេចក្តីណែនាំស្តីពី គោលការណ៍បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពី នីតិវិធីនៃការតែងតាំង និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ(២០១៥-២០២៥)

- សេចក្តីព្រាងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងសេចក្តីព្រាងផែនការរៀបចំដែនដីក្រុងព្រះសីហនុ

## ៥-ការងារបុគ្គលិក

### ៥.១-ការងារក្របខ័ណ្ឌ

គិតត្រឹមខែមករាឆ្នាំ២០១៨ ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន **១២.៨១១នាក់/ស្ត្រី ៣.១៩៧នាក់** (ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន **៩១៦នាក់/ស្ត្រី ២១២នាក់** ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន **៩.៣១៤នាក់/ស្ត្រី ២.៦៨១នាក់** ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន **៩៦៥នាក់/ស្ត្រី ១២៧នាក់** ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន **១.៦១៦នាក់/ស្ត្រី ១៧៧នាក់**) បើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ២០១៧ ចំនួនក្របខ័ណ្ឌកើនឡើងចំនួន **០៧នាក់** ។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន **១៥នាក់/ស្រី ០៤នាក់** ផ្ទេរក្របខ័ណ្ឌចេញពីក្រសួងមហាផ្ទៃចំនួន **០៤នាក់/ស្រី០១នាក់** និងលុបឈ្មោះចេញពីក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួន **០៤នាក់/ស្រី០១នាក់** ក្នុងនោះ (លុបឈ្មោះដោយមរណភាពចំនួន **០១**នាក់ លុបឈ្មោះដោយលាឈប់ពីការងារចំនួន **០៣នាក់/ស្រី ០១នាក់**)។

### ៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

ក្នុងខែមករា ឆ្នាំ២០១៨នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារចំនួន **១៥នាក់** ក្នុងនោះ (សម្រាកលំហែមាតុភាព **០៧នាក់** ស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ០៨/**ស្រី ០២នាក់**) បានអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារក្នុងអង្គភាពដើមវិញបន្ទាប់ពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន**០៥នាក់/ស្រី ០១នាក់** និងបានដាក់មន្ត្រីរាជការ ដែលត្រូវដល់អាយុចូលនិវត្តន៍ក្នុងមករា ឆ្នាំ២០១៨ មានចំនួន **១៥៩នាក់/ស្រី៣០នាក់** ក្នុងនោះ ក្របខ័ណ្ឌថ្នាក់ជាតិចំនួន**០៤នាក់/ស្រី ០១នាក់** ក្របខ័ណ្ឌរាជធានី ខេត្តចំនួន**១៣៧នាក់/ស្រី ២៧នាក់** និងក្របខ័ណ្ឌពន្ធនាគារចំនួន **១៨នាក់/ស្រី ០២នាក់**។

ទន្ទឹមនឹងនោះ ថ្នាក់ដឹកនាំក្រសួង ក៏បានផ្តល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ចំនួន **២៤៤គ្រឿង** ក្នុងនោះ គ្រឿងឥស្សរិយយស**ជាតូបការ**ចំនួន **០១**គ្រឿង គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា**តាមលំដាប់ថ្នាក់ចំនួន **១៧**គ្រឿង រួមមាន (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន **០៦**គ្រឿង ថ្នាក់មហាសេនាចំនួន **០៣**គ្រឿង ថ្នាក់ធិបឌិន្ទចំនួន **០៣**គ្រឿង ថ្នាក់សេនាចំនួន **០៥**គ្រឿង) គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ**តាមលំដាប់ថ្នាក់ចំនួន **៥៩គ្រឿង** រួមមាន (ថ្នាក់មហាសេនាចំនួន **០៦**គ្រឿង ថ្នាក់ធិបឌិន្ទចំនួន **១១**គ្រឿង ថ្នាក់សេនាចំនួន **១៤**គ្រឿង ថ្នាក់អស្សឫទ្ធិចំនួន **២៨**គ្រឿង) និង**មេដាយការងារ**តាមលំដាប់ថ្នាក់ចំនួន **១៦៧គ្រឿង** និងបានផ្តល់ប័ណ្ណសសើរចំនួន **២២**ប័ណ្ណ។

### ៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

គិតត្រឹមខែមករាឆ្នាំ២០១៨ ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនមន្ត្រីរាជការស៊ីវិលតាមមុខដំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃសរុបចំនួន **១,២៦៨រូប/ស្រី ២៤៨រូប ស្មើនឹង១៩.៥៥%**

**-មន្ត្រីរាជការស៊ីវិលសរុបមានចំនួន ៩២៧រូប /ស្រី ២១៩រូប ស្មើនឹង២៣.៧២%** ក្នុងនោះ (អគ្គនាយកចំនួន**០១រូប** អគ្គនាយករងចំនួន **២៦រូប/ស្រី០៤រូប** អគ្គលេខាធិការរងចំនួន **០៦រូប/ស្រី០២រូប** លេខាធិការដ្ឋានទីប្រឹក្សាជំនួយការចំនួន **០៦រូប/ស្រី០២រូប** ក្រុមប្រឹក្សានីតិកម្មចំនួន **១០រូប/ស្រី០២រូប** អជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចំនួន **០២រូប/ស្រី០១រូប** អង្គភាពវិភាគ និងអភិវឌ្ឍគោលនយោបាយ ការិយាល័យអន្តរវិស័យ និងសហប្រតិបត្តិការគ.ជ.អ.បចំនួន **១០រូប/ស្រី០២រូប**)

**-មន្ត្រីជាទីប្រឹក្សា និងជំនួយការសរុបមានចំនួន ៣៤១រូប/ស្រី២៩រូប ស្មើនឹង ៨.៥០%** ក្នុងនោះ (ទីប្រឹក្សាសម្តេចក្រឡាហោមចំនួន **៥៨រូប/ស្រី ០៦រូប** ជំនួយការចំនួន **៧១រូប/ស្រី ០៥រូប** ទីប្រឹក្សាក្រសួងមហាផ្ទៃចំនួន **១៨១រូប/ស្រី១៥រូប** ជំនួយការក្រសួងមហាផ្ទៃចំនួន **៣១រូប/ស្រី០៣រូប**)។ដោយឡែកក្នុងខែមករា ឆ្នាំ២០១៨នេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យសម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្ទេរភារកិច្ច និងផ្លាស់ប្តូរកន្លែងធ្វើការជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន **៤៣រូប/ស្រី១០រូប**។

### ៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

គិតត្រឹមខែមករាឆ្នាំ២០១៨ ស្ថានភាពបច្ចុប្បន្នភាពនៃចំនួនគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម៖

**-គណៈអភិបាលរាជធានី ខេត្ត សរុបចំនួន១៧៥រូប /ស្រី២៧រូប ស្មើនឹង ១៥.៤២%** ក្នុងនោះ (អភិបាលរាជធានី ខេត្តចំនួន **២៥រូប/ស្រី ០១រូប** អភិបាលរងរាជធានី ខេត្តចំនួន **១៥០រូប/ស្រី ២៦រូប**)

**-គណៈអភិបាលក្រុង ស្រុក ខណ្ឌ សរុបចំនួន ៩០៨រូប /ស្រី ១៩២រូប ស្មើនឹង ២១.១៥%** ក្នុងនោះ (អភិបាលក្រុង ស្រុក ខណ្ឌចំនួន **១៩៧រូប/ស្រី ០៧រូប** អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន **៧១១រូប/ស្រី ១៨៥រូប**)

**-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ៦,៦១៧រូប/ស្រី២,១៥៧រូប ស្មើនឹង ៣២.៥៩%** ក្នុងនោះរួមមាន៖ រចនាសម្ព័ន្ធសាលារាជធានី ខេត្តចំនួន **២,៨១៧រូប /ស្រី៨៨១រូប ស្មើនឹង ៣១.២៧%** រចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌចំនួន **៣,៨០០រូប/ស្រី១,២៧៦រូប ស្មើនឹង៣៣.៥៧%** និងប្រធានប្រកទ្វារព្រំដែនសរុបមានចំនួន **៥៤រូប /ស្រី០១រូប ស្មើនឹង ១.៨៥%**។ទន្ទឹមនេះ ក្រសួងក៏បានពិនិត្យនីត្យានុកូលភាពលើដីកាតែងតាំង ប្រគល់ភារកិច្ច ផ្ទេរភារកិច្ចមន្ត្រីរាជការបានចំនួន**១០ខេត្ត** រួមមានខេត្តបាត់ដំបង កំពង់ចាម ស្ទឹងត្រែង ត្បូងឃ្មុំ ព្រៃវែង ព្រះសីហនុ ពោធិ៍សាត់ កំពត តាកែវ និងខេត្តក្រចេះសរុបចំនួន **៩៩នាក់/ស្រី ២១នាក់**។

### ៥.៥-ការងារក្រុមប្រឹក្សា

គិតត្រឹមខែមករា ឆ្នាំ២០១៨ ស្ថានភាពបច្ចុប្បន្នភាពនៃចំនួនសមាជិករបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

**-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត**សរុបចំនួន **៣៩៣រូប /ស្រី ៥៧រូប** ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន **២៥រូប/ស្រី ០១រូប** សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន **៣៦៨រូប/ស្រី ៥៦រូប**)

**-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** សរុបចំនួន **២៩៣១រូប /ស្រី៤៣១រូប** (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **១៩៧រូប/ស្រី ០៣រូប** សមាជិកក្រុមប្រឹក្សាក្រុង ស្រុកខណ្ឌចំនួន **២៧៣៤រូប/ស្រី៤២៨រូប**)

**-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់**សរុបចំនួន **១១៥៧២រូប /ស្រី ១៩៨៤រូប** ក្នុងនោះ(មេឃុំ **១៤១០រូប** ចៅសង្កាត់ចំនួន **២៣៦រូប** ជំទប់ទី១ចំនួន**១៤១០រូប** ជំទប់ទី២ចំនួន**១៤១០រូប** ចៅសង្កាត់រងទី១ចំនួន **២៣៦រូប** ចៅសង្កាត់រងទី២ចំនួន **២៣៦រូប** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន **៦៦៣៤រូប**)។ទន្ទឹមនេះ ក្រសួងបានផ្លាស់ប្តូរនិងទទួលស្គាល់សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន **០៧រូប**/ស្រី **០២រូប**( **ដូចក្នុងឧបសម្ព័ន្ធ ១.គ**)។

### ៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល

គិតត្រឹមខែមករាឆ្នាំ២០១៨ ស្ថានភាពបច្ចុប្បន្នភាពនៃចំនួនប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលប្រវត្តិរូបក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន **៩៨២៣រូប/ស្ត្រី ២៥៤៩រូប ស្មើនឹង ២៥.៩៤%** ក្នុងនោះ មន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិដែលបានបញ្ចូលក្នុងប្រព័ត៌មានវិទ្យាមានចំនួន **៨៤៦រូប / ស្ត្រី ១៧១រូប ស្មើនឹង ២០.២១%) រួមមានដូចខាងក្រោម៖**

| | |
|---|---|
| ១.អគ្គាធិការដ្ឋាន | ចំនួន ៧៤រូប (ស្រី ០៨ រូប) |
| ២.អគ្គ.អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ចំនួន ១៨រូប (ស្រី ០២ រូប) |
| ៣.អគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង | ចំនួន ៣៧រូប (ស្រី ១១ រូប) |
| ៤.អគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម | ចំនួន ៨៧រូប(ស្រី ១៩ រូប) |
| ៥.អគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ | ចំនួន ៩១រូប (ស្រី២៧រូប) |
| ៦.ក្រុមប្រឹក្សានីតិកម្ម | ចំនួន ២០រូប (ស្រី០៣រូប) |
| ៧.អគ្គលេខាធិការដ្ឋាន | ចំនួន ១២៦រូប(ស្រី ៣០ រូប) |
| ៨.អគ្គ.ដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ចំនួន ១៤រូប (ស្រី ០២ រូប) |
| ៩.លេខាធិការដ្ឋានគ.ជ.អ.ប | ចំនួន ៣៤រូប(ស្រី ០៦ រូប) |
| ១០.អគ្គនាយកដ្ឋានរដ្ឋបាល | ចំនួន ៣៤៦រូប(ស្រី ៦៣ រូប)។ |

**មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលក្នុងប្រព័ត៌មានវិទ្យាបានចំនួន២៥រាជធានី ខេត្ត សរុបចំនួន ៨៩៧៧ រូប/ស្ត្រី ២៣៧៧រូប ស្មើនឹង ២៦.៤៧%)**។ ដោយឡែកក្នុងខែមករាឆ្នាំ២០១៨នេះ បាន និងកំពុងធ្វើបច្ចុប្បន្នភាពដោយបញ្ចូលព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា គឺខេត្តក្រចេះ

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានធ្វើសំណើគោរពជូនឯកឧត្តមប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងបានធ្វើសំណើចាត់បញ្ជូនអនុប្រធាននាយកដ្ឋានទទួលបន្ទុកបុគ្គលិក និងប្រធានការិយាល័យ នៅគ្រប់នាយកដ្ឋានទាំងប្រាំពីរ ដើម្បីមកចូលរួមស្តាប់នូវការធ្វើបទបង្ហាញ ណែនាំ និងផ្សព្វផ្សាយអំពីនីតិវិធី នៃការបំពេញប្រវត្តិរូប។

## ៦-ការងារអភិវឌ្ឍន៍សមត្ថភាព

### ៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស

ក្នុងខែមករាឆ្នាំ២០១៨ អគ្គនាយកដ្ឋានរដ្ឋបាលបានចាត់បញ្ជូនមន្ត្រីរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃចូលរួមវគ្គបណ្តុះបណ្តាល និងរៀបចំកម្មវិធីផ្តល់បទបាឋកថាក្នុងប្រទេសចំនួន ០៤វគ្គ មានសិក្ខាកាមចំនួន **៥២២រូប/ស្រី ២១០រូប** ដូចខាងក្រោម៖

- បានចាត់បញ្ជូនមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃចំនួន ០៦រូប/ស្រី ០១រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលដំបូង១០៨ម៉ោង នៅសាលាភូមិន្ទរដ្ឋបាល

- បានចាត់មន្ត្រីចំនួន ០២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននៅសណ្ឋាគារហូលីដេ ខេត្តសៀមរាប

- បានចាត់មន្ត្រីចំនួន ០២រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញគ្រូឧទ្ទេស ដែលរៀបចំឡើងដោយសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ

- បានចូលរួមរៀបចំកម្មវិធីផ្តល់បទបាឋកថាដោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្រាប់ក្រុមគោលដៅជាសិស្សមន្ត្រី និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាលមានចំនួន៥១២ រូប/ស្រី ២០៩រូប

- បាន និងកំពុងរៀបចំឯកសារបណ្តុះបណ្តាលស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ក្រុង ស្រុក។

### ៦.២-ការងារអភិវឌ្ឍសមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន

ក្នុងខែមករា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស ០២វគ្គ សរុបចំនួន **០៨រូប/ស្រី ០១រូប** និងរៀបចំសំណើសុំលិខិតឆ្លងដែនចំនួន**០៦**ច្បាប់ ដូចខាងក្រោម ៖

-បានចាត់បញ្ជូនមន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃចំនួន ០១រូប ដើម្បីចូលរួមប្រឡងប្រជែងអាហារូបករណ៍ទៅសិក្សាថ្នាក់អនុបណ្ឌិត នៅព្រះរាជាណាចក្រថៃ

-បានចាត់បញ្ជូនមន្ត្រីនាយកដ្ឋានបណ្តុះបណ្តាល នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃចំនួន ០៧រូប/ស្រី ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំ និងការគ្រប់គ្រងផែនការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ " Formulation and management of Training Plan for Human Resource Development at Sub-National Administrations " នៅប្រទេសជប៉ុន។

-បានរៀបចំសំណើសុំលិខិតឆ្លងដែនផ្លូវការចំនួន ០៦ច្បាប់ ជូនមន្ត្រីរាជការក្រសួងមហាផ្ទៃ ដើម្បីចូលរួមទស្សនកិច្ច-សិក្សា នៅសាកលវិទ្យាល័យកសិកម្ម និងរុក្ខាប្រមាញ់ នៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

### ៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ

-បានផ្សព្វផ្សាយអាហារូបករណ៍"Stipendium Hungaricum Progarmme" របស់រដ្ឋាភិបាល នៃសាធារណរដ្ឋហុងគ្រី សម្រាប់ឆ្នាំសិក្សា ២០១៨-២០១៩

-បានផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររងទៅ សិក្សា នៅ Yangzhou Polytechnic College នៃសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ឆ្នាំ២០១៨

-កំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រវិមជ្ឈការ និងវិសហមជ្ឈការលេខ៣ ឆ្នាំ២០១៧

-បន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល។

## ៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍

**ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃបានដាក់ចេញនូវគោលការណ៍ណែនាំ និងសេចក្តីជូនដំណឹងដល់រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពនានា ដូចខាងក្រោម ៖**

**-រដ្ឋបាលខេត្តក្រចេះ:** ករណីអ្នកទោសជនជាតិខ្មែរឈ្មោះ **ចាន់ ស៊ុំ** បានស្លាប់នៅមន្ទីរពេទ្យទូទៅ ខេត្តបិញកឿក នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

**-ខេត្តស្វាយរៀង កំពង់ឆ្នាំង សៀមរាប កំពង់ធំ កំពង់ស្ពឺ កោះកុង ប៉ៃលិន** និង **ស្ទឹងត្រែង** ស្តីពីសមាសភាពថ្នាក់ដឹកនាំក្រសួង ដែលអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានី ខេត្ត។

-បានចូលរួម និងសម្របសម្រួលក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តស្វាយរៀង ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង ។

**-រដ្ឋបាលរាជធានី ខេត្ត** ករណី៖

- ស្នើសុំឧបត្ថម្ភគាំទ្រ និងអនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្តល់កិច្ចសហការជាមួយអ្នករៀបចំកម្មវិធីប្រឡងសំនៀងជនពិការកម្ពុជាពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- សំណើសុំអញ្ជើញឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ចូលរួមក្នុងពិធីសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- សំណើសុំអញ្ជើញប្រធានក្រុមប្រឹក្សា និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ចូលរួមក្នុងពិធីប្រកាសឱ្យប្រើប្រាស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។
- សំណើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានី ខេត្ត និងក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាន (រាជធានី ខេត្ត) ក្នុងការជួយដឹកស្រូវប្រជាកសិករមកកន្លែងប្រមូលផ្តុំនៅរដូវប្រមូលផលស្រូវ។

-រដ្ឋបាលរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រៃវែង ករណីព្រះមហាក្សត្រ ស្តេចយាងសួរសុខទុក្ខ និងប្រោសព្រះរាជទានព្រះរាជអំណោយដល់ប្រជាកសិករក្រីក្រ នៅឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** ករណីសំណើសុំធ្លាក់ត្រាចំនួន **០៣**គ្រឿងគឺរបស់រដ្ឋបាលសង្កាត់ភ្នំពេញថ្មី,គណបក្សមាតុភូមិយើង និងធ្លាក់ត្រាស្ទួតរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដើម្បីផលិតប័ណ្ណព្រំដែនក្នុងដែនសមត្ថកិច្ចរដ្ឋបាលខេត្តឧត្តរមានជ័យ។

-**ក្រុមហ៊ុន សៀងហៃ វីហ្សេត ខូអិលធីឌី** ករណីសំណើសុំដាក់សាខាឆ្នោតសៀងហៃ នៅក្នុងទីតាំងក្រុមហ៊ុនអេស៊ាឃែសអិចប្រេសខូអិលធីឌីនៅក្នុងរាជធានីខេត្តទូទាំងប្រទេសសម្រាប់ដំណើរការអាជីវកម្មឆ្នោតសៀងហៃ។

### ៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន**០១** ខេត្ត**២៤** ខណ្ឌ**១២** ក្រុង**២៦** ស្រុក **១៥៩** សង្កាត់ **២៣៦** ឃុំ **១.៤១០** និងភូមិចំនួន **១.៤៣៨៣**។

### ៧.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

ក្រសួងមហាផ្ទៃបានស្នើទៅរាជរដ្ឋាភិបាលកម្ពុជា ករណីផ្តល់**មេដាយព្រះរាជាណាចក្រកម្ពុជា**ចំនួន**០៣**គ្រឿង គឺថ្នាក់មហាសេរីវឌ្ឍន៍ចំនួន **០១**គ្រឿង ថ្នាក់មហាសេនាចំនួន **០២**គ្រឿង **មេដាយមុនីសារាភ័ណ្ឌ**ចំនួន **០៩**គ្រឿង គឺថ្នាក់មហាសេនាចំនួន **០៤**គ្រឿង និងថ្នាក់ធិបឌិន្ទចំនួន **០៥**គ្រឿង **មេដាយសេនាជ័យសិទ្ធ**ចំនួន **១០**គ្រឿង **មេដាយស្ថាបនាជាតិ**ចំនួន **១៨**គ្រឿង គឺមេដាយមាសស្ថាបនាជាតិចំនួន **១៨**គ្រឿង ផ្តល់ជូនមន្ត្រីរាជការ និងសប្បុរសជន ដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តព្រៃវែង ដោយចំណាយអស់ថវិកាសរុបចំនួន **១.០៩១.២១០ ដុល្លារ** (មួយលានកៅសិបមួយពាន់ពីររយដប់ដុល្លារសហរដ្ឋអាមេរិក) **(ដូចក្នុងឧបសម្ព័ន្ធ ២)**។

### ៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

#### ៧.៤.១-ការងារកម្មវិធីគាំទ្រដោយ UNICEF

-បានពិនិត្យ និងបូកសរុបរបាយការណ៍វគ្គបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលបញ្ហាពិការភាពក្នុងអភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ។

-បែងចែកសៀវភៅទិនានុលេខន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

-បានប្រជុំជាមួយអង្គការយូនីសេហ្វ រៀបចំផែនការសកម្មភាពការងារពិការភាព សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៨។

-បានប្រជុំជាមួយអង្គការយូនីសេហ្វ ដើម្បីពិនិត្យ និងរចនាសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់។

-ប្រជុំជាមួយអង្គការយូនីសេហ្វ ដើម្បីរៀបចំសេចក្តីណែនាំដល់ខេត្តរតនគិរីសម្រាប់ការអនុវត្តសេវាសង្គមពាក់ព័ន្ធនឹងអាហារូបត្ថម្ភ។

-ចូលរួមប្រជុំជាមួយអង្គការ UNICEF ស្តីពីការត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលពិការភាពក្នុងអភិបាលកិច្ចថ្នាក់ក្រោមជាតិ ដែលធ្វើនៅខេត្តចំនួន ០២គឺ ខេត្តសៀមរាប និងខេត្តបាត់ដំបង ព្រមទាំងត្រៀមរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងផងដែរ។

#### ៧.៤.២-ការងារកម្មវិធីគាំទ្រដោយ GGGI

-ពិនិត្យសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងនីរន្តរភាព ២០១៨-២០៣០។

### ៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់

#### ៧.៥.១-គម្រោងមូលនិធិក្រុង ស្រុក

គិតត្រឹមខែមករាឆ្នាំ២០១៨នេះ ការរៀបចំសំណើគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៧ សរុបមានចំនួន **៣២៦គម្រោង** ដែលក្នុងនោះ រួមមាន៖ គម្រោងដែលបានចុះកិច្ចសន្យាសាងសង់ចំនួន **១៩៦**គម្រោង (ស្មើនឹង ៦០%) គម្រោងត្រូវបានបញ្ចប់ការរៀបចំចំនួន **៥៧**គម្រោង (ស្មើនឹង ១៨%) គម្រោងកំពុងបន្តការសិក្សាចំនួន **៦៥**គម្រោង (ស្មើនឹង២០%) និងគម្រោងមិនទាន់ចាប់ផ្តើមសិក្សាចំនួន ៨គម្រោង (ស្មើនឹង២%)។

#### ៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់

ក្នុងខែមករា ឆ្នាំ២០១៨នេះ សំណើគម្រោង សរុបចំនួន **១.៧៥៤គម្រោង** រួមមាន៖ បានចុះកិច្ចសន្យាសាងសង់ចំនួន**១៥៤៥**គម្រោង(ស្មើនឹង៨៨%)បានបញ្ចប់ការរៀបចំគម្រោងចំនួន**១៧៣**គម្រោង(ស្មើនឹង ៩%)

គម្រោងកំពុងបន្តការសិក្សាចំនួន **២៧**គម្រោង (ស្មើនឹង២%)។ គម្រោងដែលបានចុះកិច្ចសន្យាឆ្នាំ២០១៧សរុបចំនួន **១៥៤៥**កិច្ចសន្យា ក្នុងនោះកិច្ចសន្យាដែលបានបញ្ចប់ការសាងសង់ចំនួន **៥៩៥** (ស្មើនឹង៣៩%) កិច្ចសន្យាដែលអនុវត្តបានលើសពី៥០%ចំនួន **២១៥** (ស្មើនឹង ១៤%) កិច្ចសន្យាដែលអនុវត្តបានតិចជាង៥០% ចំនួន **១៥៦** (ស្មើនឹង ១០%) និងកិច្ចសន្យាដែលមិនទាន់បានអនុវត្តចំនួន **៥៧៩** (ស្មើនឹង ៣៧%)។ ដោយឡែកសម្រាប់ឆ្នាំ២០១៦ គម្រោងដែលបានចុះកិច្ចសន្យាសរុបចំនួន **១.៧១៣**កិច្ចសន្យា ក្នុងនោះកិច្ចសន្យាដែលបានបញ្ចប់ការសាងសង់ចំនួន **១៦០២** (ស្មើនឹង ៩៣.៥%) កិច្ចសន្យាដែលអនុវត្តបានលើសពី៥០% ចំនួន **៧១** (ស្មើនឹង ៤.១%) កិច្ចសន្យាដែលអនុវត្តបានតិចជាង៥០% ចំនួន **២៨** (ស្មើនឹង ១.៦%) កិច្ចសន្យាដែលមិនទាន់បានអនុវត្តចំនួន **៥** (ស្មើនឹង ០.៤%) និងអ្នកទទួលការបោះបង់ចោលចំនួន **៧** (ស្មើនឹង ០.៤%)។

### ៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន

#### ៧.៦.១-ការផ្ទេរមុខងារ និងធនធាន

-បានចូលរួមរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីទិន្នន័យដើមគ្រា នៃការអនុវត្តមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា នៅខេត្តកំពត

#### ៧.៦.២-ការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ

គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ការិយាល័យច្រកចេញចូលតែមួយទាំង**៥២**គោលដៅបានផ្តល់សេវារដ្ឋបាលសរុបចំនួន **៥៧.១៤៧សេវា** ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង ១៤ ឃើញថា **វិស័យនីត្យានុកូលកម្ម**បានផ្តល់សេវាបានច្រើនជាងគេគឺ **២៧.០៤០**សេវា (ស្មើនឹង៤៧,៣២% នៃសេវាសរុប) បន្ទាប់មក**វិស័យអគ្រានុកូលដ្ឋាន**ចំនួន**១៧.៩៣១**សេវា(៣១,៣៨%) ចំនែកវិស័យឧស្សាហកម្ម និងសិប្បកម្មផ្តល់សេវាបានចំនួនតិចជាងគេគឺ **២៧**សេវា(០,០៥%) **(ដូចក្នុងឧបសម្ព័ន្ធ៣)**។ រយៈពេលដូចគ្នានេះដែរ ការិយាល័យច្រកចេញចូលតែមួយទាំង **៥២**គោលដៅ ទទួលបានចំណូលសេវារដ្ឋបាលសរុបចំនួន **១.៤៧៨.១២០.៨៤៤រៀល** (**ស្មើនឹង៣៦៩.៥៣០,២១ដុល្លារអាមេរិក**) ដែលក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា**វិស័យសុរិយោដី**មានចំណូលខ្ពស់ជាងគេគឺ **៨៤៧.១៧០.០០០ រៀល** (ស្មើនឹង៥៧,៣១%) បន្ទាប់មក**វិស័យសំណង់ ២៥០.៤៧៤.០០០រៀល** (ស្មើនឹង១៦,៩៥%) ចំណែកវិស័យឧស្សាហកម្មនិងសប្បកម្មមានចំណូលតិចជាងគេគឺ**១.៣៥០.០០០រៀល**(ស្មើនឹង០,០៩%) ចំពោះវិស័យអគ្រានុកូលដ្ឋាន បានផ្តល់សេវាជូនប្រជាពលរដ្ឋដោយមិនគិតកម្រៃសេវា **(ដូចក្នុងឧបសម្ព័ន្ធ ៤)**។

ទន្ទឹមនេះ **អគ្គនាយកដ្ឋានរដ្ឋបាល** បានសហការសម្របសម្រួល និងគាំទ្រលើដំណើរការនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-បានចុះទៅពិភាក្សា អំពីការរៀបចំទីកន្លែងធ្វើការរបស់អង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋរបស់រដ្ឋបាលខេត្តកំពត

-បានទំនាក់ទំនងទៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលដីកា សេចក្តីសម្រេចតែងតាំងមន្ត្រីដែលបម្រើការងារ និងការបំពាក់ឧបករណ៍ សម្ភារ បរិក្ខានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-បានជូនដំណឹងទៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ឱ្យត្រៀមរៀបចំដាក់ឱ្យដំណើរការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តសម្រាប់ការផ្តល់សេវានៅរដ្ឋបាលរាជធានី ខេត្ត

-បានតាមដានដំណើរការសាងសង់អគារ និងការបំពាក់សម្ភារៈរបស់ការិយាល័យច្រកចេញចូលតែមួយចំនួន០៣ គោលដៅក្នុងចំណោម០៦ថ្មីសម្រាប់ឆ្នាំ២០១៧

-បានរៀបចំ និងបញ្ចប់របាយការណ៍ចុះសិក្សាបង្កើតការិយាល័យច្រកចេញចូលតែមួយចំនួន៣០ សម្រាប់ឆ្នាំ២០១៨។

### ៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០១៨ ការិយាល័យប្រជាពលរដ្ឋទាំង**៥២**គោលដៅ បានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធជាមួយនឹងការិយាល័យច្រកចេញចូលតែមួយសរុបចំនួន **៦៦១**ករណី ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន **១៩**ករណី (បញ្ចប់ការដោះស្រាយ **១៩**ករណី និងកំពុងដោះស្រាយ ០ករណី) បណ្តឹងក្រៅសមត្ថកិច្ចចំនួន **២៧**ករណី សំណូមពរ និងការទិតៀនចំនួន **១២២**ករណី ការសរសើរចំនួន**៦០**ករណី ការសាកសួរព័ត៌មានផ្សេងៗចំនួន **៤៣៣**ករណី(ក្នុងសមត្ថកិច្ច **៤១៣**ករណី និងក្រៅសមត្ថកិច្ច **២០**ករណី)(**ដូចក្នុងឧបសម្ព័ន្ធ ៥**)។

ចំពោះលទ្ធផល នៃការដោះស្រាយបណ្តឹងតវ៉ា ដោយក្រុមការងារគណនេយ្យភាពរាជធានី ខេត្តចាប់ពីថ្ងៃទី ០១ **ខែមករា ឆ្នាំ**២០១៨ រហូតដល់ថ្ងៃទី២០ **ខែមករា ឆ្នាំ**២០១៨ ទទួលបានលទ្ធផលដូចខាងក្រោម៖

| **ការបរិយាយ** | **ចំនួន** | **គិតជា%** |
|---|---|---|
| *ការបើកប្រអប់សំបុត្រ* | *១០១៧ លើក* | *៤៤%* |
| *កិច្ចប្រជុំក.គ.ខ* | *២៩លើក* | *៤%* |
| *កិច្ចប្រជុំក្រុមគាំទ្រ ក.គ.ខ* | *០ លើក* | *០%* |
| *ពាក្យបណ្តឹងដែលប្រមូលបានសរុប* | *១៩ ករណី* | *១០០%* |
| *- ពាក្យបណ្តឹងត្រូវដោះស្រាយ* | *៩ ករណី* | *៤៧%* |
| *+ ដោះស្រាយរួច* | *៥ ករណី* | *៥៦%* |
| *+កំពុងដោះស្រាយ* | *៤ ករណី* | *៤៤%* |
| *- ពាក្យបណ្តឹងមិនត្រូវដោះស្រាយ* | *១០ ករណី* | *៥៣%* |

ទន្ទឹមនេះ **អគ្គនាយកដ្ឋានរដ្ឋបាល** ក៏បានអនុវត្តការងារចាំបាច់មួយចំនួនដើម្បីគាំទ្រដល់ការដោះស្រាយវិវាទនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការិយាល័យប្រជាពលរដ្ឋដូចខាងក្រោម៖

-ដាក់ចេញលិខិតឆ្លើយតបទៅរដ្ឋបាលខេត្តចំនួន០៦ឱ្យបន្តនីតិវិធីរៀបចំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរួមមាន (ខេត្តកំពង់ឆ្នាំង កំពង់ចាម បាត់ដំបង កំពត កណ្តាល និងខេត្តមណ្ឌលគិរី)

-បានធ្វើការតាមដាន និងគាំទ្រដំណើរការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-តាមដានដំណើរការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ ដែលផុតអាណត្តិការងារឱ្យរៀបចំបោះឆ្នោតឡើងវិញក្នុងនោះ មានស្រុកត្រាំកក់ ក្រុងសែនមនោរម្យ និងក្រុងស្ទឹងត្រែង

-ប្រមូលដីកាទទួលស្គាល់របស់ប្រធានការិយាល័យប្រជាពលរដ្ឋទាំង៥២ក្រុង ស្រុក ខណ្ឌ

-បានធ្វើការទំនាក់ទំនងគាំទ្រលើការអនុវត្តតួនាទីភារកិច្ច និងដំណើរការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌគោលដៅ។

## ៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា

**ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ លើវិស័យនានាឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានធ្វើលិខិតទៅក្រសួង ស្ថាប័ននានា រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពចំណុះក្រសួង ដូចខាងក្រោម៖**

-**អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ** ករណី៖

- ស្នើសុំមតិយោបល់ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-ឥណ្ឌា
- ស្នើសុំរបាយការណ៍បូកសរុបលទ្ធផលការងារស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ រវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ

-**ធនាគារជាតិនៃកម្ពុជា** ដើម្បីចូលរួមជាសមាជិកក្រុមការងារវាយតម្លៃអញ្ញមញ្ញស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភាវកម្ម និងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់(APG)

និងហិរញ្ញប្បទានភាវរកម្ម និងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់(APG)

-ចូលរួមពិនិត្យ និងផ្តល់យោបល់លើខ្លឹមសារផែនការកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ (កម្ពុជា) និងក្រសួងនគរបាល (វៀតណាម) ដែលគ្រោងនឹងចុះហត្ថលេខាក្នុងឱកាសបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា របស់រដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម នាថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៨។

**៩-ការងារតាមវិស័យផ្សេងៗ**

**៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន **៨២ច្រក** រួមមាន ច្រកទ្វារកំពង់ផែអន្តរជាតិចំនួន **០៣ច្រក** ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន **០៣ច្រក** ច្រកទ្វារព្រំដែនអន្តរជាតិចំនួន **២៣ច្រក** ច្រកទ្វារព្រំដែនទ្វេភាគីចំនួន **១៤ច្រក** ច្រកទ្វារតំបន់ព្រំដែនចំនួន **២៩ច្រក** និងច្រកទ្វារកំពង់ផែសមុទ្រចំនួន **១០ច្រក (ដូចក្នុងឧបសម្ព័ន្ធ ៦)**។

-បានរៀបចំសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការរៀបចំការសាងសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធនិងរៀបចំដាក់ឱ្យដំណើរការជាផ្លូវការច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ ស្ថិតក្នុងខេត្តព្រៃវែង។

-បានធ្វើលិខិតជូនដំណឹងដល់រដ្ឋបាលខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ករណីគំរូហត្ថលេខា និងត្រា របស់មន្ត្រីមានសមត្ថកិច្ចថៃ ក្នុងការចេញប័ណ្ណព្រំដែនជូនដល់ប្រជាពលរដ្ឋរបស់ខ្លួន ដែលរស់នៅក្នុងខេត្តឧប៊ុនរាជធានី និងខេត្តស៊ីសាកេត។

**៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

**ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានដាក់ចេញនូវគោលការណ៍ណែនាំ និងបានអនុញ្ញាតជាគោលការណ៍ឱ្យរដ្ឋបាលរាជធានីខេត្តចុះអនុស្សរណៈយោគយល់គ្នា (MOU) និងធ្វើទស្សនៈកិច្ចសិក្សាដូចខាងក្រោម៖**

បានរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីត្រៀមរៀបចំសម្របសម្រួលខ្លឹមសារកំណត់ហេតុ នៃកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨។

**-រដ្ឋបាលខេត្តសៀមរាប** ករណីដំណើរទស្សនកិច្ចរបស់អនុប្រធានាធិបតីមីយ៉ាន់ម៉ា នៅខេត្តសៀមរាប នាថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨។

**-រដ្ឋបាលខេត្តបាត់ដំបង** ករណី៖

▪ សំណើសុំគោលការណ៍អនុញ្ញាតអញ្ជើញគណៈប្រតិភូក្រុងយូលីន ខេត្តក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិនមកបំពេញទស្សនកិច្ចនៅខេត្តបាត់ដំបងក្នុងអំឡុងសប្តាហ៍ទី០៤ ខែធ្នូ ឆ្នាំ២០១៧ ឬខែមករា ឆ្នាំ២០១៨

▪ សំណើសុំគោលការណ៍អនុញ្ញាតអញ្ជើញគណៈប្រតិភូខេត្តហ៊ីណាន នៃសាធារណរដ្ឋប្រជាមានិតចិនមកបំពេញ ទស្សនកិច្ចនៅខេត្តបាត់ដំបង។

**-រដ្ឋបាលបាត់ដំបង និងខេត្តកែប** ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យអភិបាលនៃគណៈអភិបាលបាត់ដំបង និងអភិបាលខេត្តកែបដឹកនាំគណៈប្រតិភូទៅចូលរួមក្នុងពិធីចែកទ្បាបិលជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ាន នាឱកាសវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០១៨ នៅទីក្រុងឈៀងម៉ៃនៃព្រះរាជាណាចក្រថៃចាប់ពីថ្ងៃទី២៥-២៧ខែមករា ឆ្នាំ២០១៨

**-រដ្ឋបាលខេត្តកែប** ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យឯកឧត្តម **កែន សត្ថា** អភិបាលនៃគណៈអភិបាលខេត្តកែបដឹកនាំគណៈប្រតិភូទៅចូលរួមកម្មវិធី " ជួបជុំក្រុមអតីតជំនាញការវៀតណាម ៩៩០២ ខេត្តសុកចាំង(១៩៧៩-១៩៨៩) " នៅខេត្តសុកចាំង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

**-រដ្ឋបាលខេត្តកោះកុង** ករណីរាជរដ្ឋាភិបាលបានអនុញ្ញាតជាគោលការណ៍ ឱ្យរដ្ឋបាលខេត្តកោះកុងចងសម្ព័ន្ធមេត្រីភាពជាមួយខេត្តជីលីន នៃសាធារណរដ្ឋប្រជាមានិតចិន។

**-រដ្ឋបាលខេត្តព្រះវិហារ** ករណី៖

▪ ស្នើសុំគោលការណ៍អនុញ្ញាតដឹកនាំគណៈប្រតិភូខេត្តព្រះវិហារទៅបំពេញទស្សនកិច្ច នៅទីក្រុងលីជាំង ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

▪ ស្នើសុំគោលការណ៍អនុញ្ញាតពិនិត្យសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំលើកទី៧ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់នៅតាមបណ្តោយព្រំដែន និងកិច្ចសហប្រតិបត្តិការរួមគ្នាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរវាងខេត្តព្រះវិហារ និងចំប៉ាសាក់។

### ៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

ក្នុងខែមករា ឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងលើសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍឆ្នាំ២០១៧ចំនួន **១៤១គម្រោង** មានទឹកប្រាក់សរុបចំនួន **៦៩២.៥០១.៣៨៩.៨០០ រៀល** ពីរដ្ឋបាលខេត្តចំនួន **១២** រួមមានៈ រាជធានីភ្នំពេញ(៨០គម្រោង) ខេត្តកណ្តាល (១៥គម្រោង) ខេត្តកំពង់ឆ្នាំង(០៧គម្រោង) ខេត្តបាត់ដំបង(១១គម្រោង) ខេត្តប៉ៃលិន(០១គម្រោង) ខេត្តបន្ទាយ-មានជ័យ (០៥គម្រោង) ខេត្តកំពង់ស្ពឺ (០៦គម្រោង) ខេត្តកែប (០២គម្រោង) ខេត្តកោះកុង (០១គម្រោង) ខេត្តត្បូងឃ្មុំ(០៩គម្រោង) ខេត្តស្ទឹងត្រែង(០២គម្រោង) និងក្រចេះ(០២គម្រោង) (**ដូចក្នុងឧបសម្ព័ន្ធ ៧**)។ ទន្ទឹមនឹងនោះ ថ្នាក់ដឹកនាំក្រសួងបានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០១៧ ចំនួន៣៦គម្រោង មានទឹកប្រាក់សរុបចំនួន **១០៣.០៦៤.១៦៣.៥០០រៀល** របស់រដ្ឋបាលរាជធានី ខេត្តចំនួន៦ រួមមាន រាជធានីភ្នំពេញ(២៥គម្រោង) ខេត្តកណ្តាល(០២គម្រោង) ខេត្តបន្ទាយមានជ័យ(០៣គម្រោង) ខេត្តកំពង់ស្ពឺ(០១គម្រោង) ខេត្តកែប(០២គម្រោង) ខេត្តកោះកុង(០១គម្រោង) **(ដូចក្នុងឧបសម្ព័ន្ធ ៨)**។

**-រដ្ឋបាលខេត្តកណ្តាល បាត់ដំបង ពោធិ៍សាត់ ប៉ៃលិន ឧត្តរមានជ័យ កំពង់ចាម ក្រចេះ មណ្ឌលគិរី រតនគិរី និងរាជធានីភ្នំពេញ** ករណីការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តនីតិវិធី នៃការរៀបចំ និងការអនុវត្តគម្រោងរបស់រដ្ឋបាលរាជធានី ខេត្តក្នុងឆ្នាំ២០១៧។

ទន្ទឹមនេះ ក្រសួងមហាផ្ទៃ ក៏បានធ្វើលិខិតជម្រាបជូនអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ករណីសំណើសុំវិនិយោគរមណីយដ្ឋានបឹងយក្សឡោម ដែលមានផ្ទៃដីទំហំ ២៨០ហិកតា និងផ្ទៃបឹងទំហំ ៥០,២៤ហិកតា។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

បច្ចុប្បន្ន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃសរុបមានចំនួន **៥.២៥៦** ក្នុងនោះ (សមាគមចំនួន **២.១៣៤** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន **៣.១២២**)។ ដោយឡែកក្នុងខែមករាឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងបញ្ជីមានចំនួន **២២** សមាគមចំនួន **១៧** (ក្នុងនោះសហគមន៍ជនជាតិដើមភាគតិច ០៣) និងអង្គការមិនមែនរដ្ឋាភិបាលចំនួន **០៥** និងបានបញ្ចូលទិន្នន័យ ស្កេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគមចំនួន **៦៤ច្បាប់**។

ក្រៅពីនេះក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានា ដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃរចនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំប្តូរអាសយដ្ឋាននៃទីស្នាក់ការកណ្តាល ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ និងការផ្អាកសកម្មភាពបណ្តោះ

អាសន្នចំពោះសមាគម អង្គការមិនមែនរដ្ឋាភិបាលតាមបទប្បញ្ញត្តិ ដែលកំណត់ដោយច្បាប់។ ជាមួយគ្នានេះដែរ ក៏បានបញ្ជូនប្រកាស និងសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃទៅឱ្យសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន **២៩ច្បាប់** ក្នុងនោះ (សមាគមចំនួន **២០ច្បាប់** អង្គការមិនមែនរដ្ឋាភិបាលចំនួន **០៩ច្បាប់**)។

ជាមួយគ្នានេះដែរ ក៏បានពិនិត្យ និងបូកសរុបអំពីការបំពេញកាតព្វកិច្ចរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**៩.៤.២-ការងារគណបក្សនយោបាយ**

ក្នុងខែមករាឆ្នាំ២០១៨ គណបក្សនយោបាយមានចំនួនសរុប **៣៦គណបក្ស** ក្នុងនោះគណបក្សនយោបាយ ដែលបានចុះឈ្មោះក្នុងបញ្ជីចំនួន **៣៥គណបក្ស** និងគណបក្សនយោបាយបានបង្កើតចំនួន **០១គណបក្ស**។

ទន្ទឹមនេះ ក្រសួងបានធ្វើលិខិតឆ្លើយតបទៅក្រសួងយុត្តិធម៌ អំពីការផ្តល់ឯកសារគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងការចូលរួមសកម្មភាពជាមួយគណសង្គ្រោះជាតិ។

## II-បញ្ហាប្រឈម និងសំណូមពរ

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមកអគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-ការបញ្ជូនឯកសារពីក្រសួងមហាផ្ទៃទៅកាន់រដ្ឋបាលរាជធានី ខេត្ត និងការបញ្ជូនឯកសារពីរដ្ឋបាលរាជធានី ខេត្ត មកក្រសួងមហាផ្ទៃ នៅតែមានភាពយឺតយ៉ាវ។

-ការផ្គត់ផ្គង់សម្ភារការិយាល័យដូចជាក្រដាស ទឹកថ្នាំ ម៉ាស៊ីនថតចម្លង ពុំបានគ្រប់គ្រាន់តាមតម្រូវការការងារ និងមានភាពយឺតយ៉ាវ។

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្តនានាមានភាពយឺតយ៉ាវពុំឆ្លើយតបទៅនឹងតម្រូវការឱ្យទាន់ពេលវេលា ដោយមន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុន។

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារអគ្គនាយកដ្ឋានរដ្ឋបាល សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់បំពេញការងារ។

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនបន្ទាប់ពីចុះបេសកកម្ម។

## III-ទិសដៅការងារបន្ត

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការកំណត់ អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់**ខែកុម្ភៈ ឆ្នាំ២០១៨** ដូចខាងក្រោម៖

**១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**១.១-លិខិតបទដ្ឋានគតិយុត្តិដែលកំពុងរៀបចំផ្ទៃក្នុង**

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសស្តីពី ការបង្កើតទីចាត់ការទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិក្នុងរចនាសម្ព័ន្ធសាលាខេត្តព្រះសីហនុ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាល របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

- សេចក្តីព្រាង សេចក្តីណែនាំស្តីពី នីតិវិធីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

- សេចក្តីព្រាងសេចក្តីណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- សេចក្តីព្រាងសៀវភៅណែនាំស្តីពី "កិច្ចការរដ្ឋបាល" សម្រាប់ប្រើប្រាស់នៅតាមអង្គភាព (ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ

- សេចក្តីព្រាងបឋមផែនការយុទ្ធសាស្ត្រសម្រាប់ការរៀបចំបង្កើត និងការគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន

- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីអធិការកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ

- សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ នៃទីស្តីការក្រសួងមហាផ្ទៃ និងមន្ត្រីរាជការ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**១.២-លិខិតបទដ្ឋានគតិយុត្តិដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែក នៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលការគណនារបបសោធននិវត្តន៍ជន និងជនបាត់បង់សមត្ថភាពការងារចំពោះយោធិន និងមន្ត្រីនគរបាលជាតិ

- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាល ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អត្រាភាគទានបែបបទនិងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន

- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម

- សេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម

សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

- សេចក្តីព្រាងសេចក្តីណែនាំស្តីពីគោលការណ៍បែបបទ និងនីតិវិធី នៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពី នីតិវិធីនៃការតែងតាំង និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ(២០១៥-២០២៥)

- សេចក្តីព្រាងយុទ្ធសាស្ត្រជាតិសមាហរណកម្មតំបន់ឆ្នេរ និងសេចក្តីព្រាងផែនការរៀបចំដែនដីក្រុងព្រះសីហនុ។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-រៀបចំបែបបទសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ២០១៨ ជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

- រៀបចំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាសម្រាប់ឆ្នាំ២០១៨

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ មកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រី ពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើមដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មី និងអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដើម្បីសុំពិនិត្យនីត្យានុកូលភាព លើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកប័ត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ដែលបានប្រឡងជាប់ជាស្ថាពរក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ឆ្នាំ២០១៧

-ត្រៀមប្រកាសលទ្ធផលប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ឆ្នាំ២០១៧។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-បន្តរៀបចំការដាក់មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ដែលដល់អាយុចូលនិវត្តន៍ក្នុងខែមករាដល់ខែមិថុនា ឆ្នាំ២០១៨

-រៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាព

-រៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលសុំលាឈប់ពីការងាររដ្ឋ

-រៀបចំបែបបទដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស តាមការស្នើសុំ

-រៀបចំសំណុំលិខិតអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញបន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស តាមការស្នើសុំ

-រៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-រៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ដោយហួសកាលកំណត់

-រៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ធានារ៉ាប់រងសង្គម

-ពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយស មេដាយការងារ និងប័ណ្ណសសើរជូនមន្ត្រីរាជការស៊ីវិល

-រៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-ត្រួតពិនិត្យមន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ដែលឈប់ហួសកាលកំណត់ ដើម្បីស្នើសុំលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល។

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយស មេដាយការងារ ការស្នើសុំប័ណ្ណសរសើរជូនមន្ត្រីរាជការស៊ីវិល

-រៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តត្រួតពិនិត្យមន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដែលឈប់ហួសកាលកំណត់ ដើម្បីស្នើសុំលុបឈ្មោះចេញពីក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-កំពុងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមុខតំណែង និងចំនួនមន្ត្រីនៅតាមមុខតំណែង នៃអង្គភាពនីមួយៗ ផ្លាស់ប្តូរកន្លែងធ្វើការ រៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្សដោយបញ្ញត្តិរយៈពេល០៣ខែ រៀបចំតារាងបៀវត្សកែតម្រូវឱ្យត្រូវតាមរចនាសម្ព័ន្ធ នៃអង្គភាពនីមួយៗ

-រៀបចំធ្វើបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារឱ្យមានភាពត្រឹមត្រូវ នៅទីស្តីការក្រសួងមហាផ្ទៃ

-បន្តការងារគ្រប់គ្រងទិន្នន័យ និងស្រង់ឈ្មោះបុគ្គល ដែលបានជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមវេនសម្រាប់ឆ្នាំ២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ

-តាមដានបញ្ជីវត្តមានប្រចាំខែមន្ត្រីរាជការស៊ីវិល នៅតាមនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-ពិនិត្យ និងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការផ្ទេរ និងចាត់តាំងបុគ្គលិក ដែលជាមន្ត្រីរាជការស៊ីវិល ក្របខ័ណ្ឌក្រសួងមហាផ្ទៃឱ្យទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ និង ០៨ឆ្នាំរបស់ខ្លួន

-បន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ លើការពិពណ៌នាមុខតំណែងគ្រប់គ្រង និងវិជ្ជាជីវៈ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅរាជធានី និងខេត្តសៀមរាប

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការ នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

-ត្រៀមសិក្សា លើការរៀបចំការពិព័ណ៌នាមុខដំណែង និងលក្ខខណ្ឌការងារ និងចុះសិក្សាវាយតម្លៃអំពីលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តលក្ខខណ្ឌការងាររបស់មន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ត្រៀមកសាងជូនដំណឹងទៅរាជធានី ខេត្ត ពាក់ព័ន្ធ នឹងមន្ត្រីរាជការដែលស្ថិតក្នុងការចោទប្រកាន់តាមផ្លូវតុលាការ

-សិក្សារៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹង ប្រព័ន្ធវាយតម្លៃគុណផល និងប្រព័ន្ធវាយតម្លៃមន្ត្រី រាជការផ្អែកលើគុណផលការងារ

-សហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយ លើការងារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបបកំណត់រយៈពេល ០២ ឆ្នាំ សម្រាប់ឆ្នាំ២០១៧

-ធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-កសាងលិខិតណែនាំទៅរាជធានី ខេត្ត ពាក់ព័ន្ធនឹងនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-ពិនិត្យឯកសារលក្ខខណ្ឌការងាររបស់មន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-រៀបចំប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធការងារ រវាងនាយកដ្ឋានបុគ្គលិក និងរាជធានី ខេត្ត ដើម្បីគាំទ្រការងារក្រុមប្រឹក្សា

-បន្តយកចិត្តទុកដាក់ពិនិត្យ លើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

-ជំរុញដំណើរការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំបែបបទនិងនីតិវិធីនៃការផ្លាស់ប្តូរ និងចេញប័ណ្ណសម្គាល់ខ្លួនរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-បន្តធ្វើបច្ចុប្បន្នភាពដោយបញ្ចូលព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាបន្តបន្ទាប់

-បន្តជំរុញតាមបណ្តាអង្គភាពនានាទាំងថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិដែលមិនទាន់បានបញ្ជូនប្រវត្តិរូបឱ្យបានទាន់ពេលវេលា។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

- បន្តរៀបចំសេចក្តីព្រាងឯកសាបណ្តុះបណ្តាលស្តីពីប្រព័ន្ធហិរញ្ញវត្ថុក្រុង ស្រុក

- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងមន្ត្រីរាជការថ្មីក្របខ័ណ្ឌឆ្នាំ២០១៧

- ត្រៀមរៀបចំអនុវត្តកម្មវិធីបណ្តុះបណ្តាលសាកល្បងរបស់ NASLA សម្រាប់ក្រុមគោលដៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

- បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីរាជការទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

- បន្តរៀបចំបែបបទ នីតិវិធី នៃការស្នើសុំលិខិតឆ្លងដែនផ្លូវការ និងលិខិតឆ្លងដែនការទូត តាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បន្តសហការជាមួយដៃគូដើម្បីស្វែងរកការគាំទ្រនិងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

- បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ "វិមជ្ឈការ និងវិសហមជ្ឈការ"

- បន្តសហការជាមួយអ្នកជំនាញកុំព្យូទ័រ គ.ជ.អ.ប ដើម្បីដំណើរការវេបសាយរបស់អគ្គនាយកដ្ឋានរដ្ឋបាល

- បន្តធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋានរដ្ឋបាល។

**៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៤.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំការអនុញ្ញាតកាត់ដីរួមនៅក្នុងភូមិតាព្រហ្ម ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជូនប្រជាពលរដ្ឋចំនួន **៦៩**គ្រួសារ។

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំជួយអន្តរាគមន៍ និងកែប្រែករណីលិខិតលេខ១២៣២ សជណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ដែលបានដកហូតយកដីរបស់ឈ្មោះ **សន ថន** ចំនួន **២៥០០**ហិកតា នៅឃុំឆ្នាល់មាន់ ឃុំដូនបា និងឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង និងសុំអន្តរាគមន៍ទៅលោក **ស៊ូ អាហ៊ាហ្មាត់** អភិបាលរងខេត្តបាត់ដំបងឱ្យចូលខ្លួនដោះស្រាយរឿងយកប្រាក់ចំនួន **២៥០០០**ដុល្លារអាមេរិក ដើម្បីរត់ការធ្វើប្លង់រឹង បែរជារត់ការយកដីរបស់គាត់ និងស្នើសុំជួយអន្តរាគមន៍ទៅលោក **ទា គីមហុង** ទីប្រឹក្សាសម្តេចក្រឡាហោមឱ្យចូលខ្លួនដោះស្រាយរឿងយកប្រាក់ចំនួន **៤០០០០**ដុល្លារអាមេរិក ដើម្បីចេញសជណថ្មី។

-បន្តពិនិត្យ និងលើកយោបល់ ករណីដោះស្រាយទំនាស់ដីធ្លីរវាងអ្នកស្រី **ចាន់ ហឿ** តំណាងឱ្យប្រជាពលរដ្ឋចំនួន **៣៨**គ្រួសារ ប្តឹងលោក**លឹម ទាឡេង** និងលោក **ហែល ហឿន** ទាមទារដីទំហំ **១៥៩**ហិកតា នៅភូមិកាប់ព្រិច និងភូមិកុយវែង ឃុំព្រះផុស ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។

-បន្តរៀបចំលិខិតជម្រាបទៅរដ្ឋបាលរាជធានីខេត្តស្តីពីសមាសភាពថ្នាក់ដឹកនាំក្រសួងដែលនឹងអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តរៀបចំគាំទ្រដល់ដំណើរការសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តរៀបចំសមាសភាពបន្ថែមក្នុងគណៈកម្មការស្រាវជ្រាវកែសម្រួលព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

-បន្តពិនិត្យ និងលើកយោបល់ករណីសំណើសុំបង្កើតភូមិថ្មីចំនួន ០១ ស្ថិតក្នុងឃុំបុសលាវ ភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំថ្មី និងភូមិថ្មីចំនួន ០៣ ស្ថិតក្នុងឃុំចង្រ្កង់ ស្រុកចិត្របុរី និងភូមិថ្មីចំនួន ០២ ស្ថិតក្នុងឃុំដំរីផុងស្រុកឆ្លូង ខេត្តក្រចេះ។

**៤.៣-ការងារផ្ដល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដានត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ ស.ជ.ណ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការពង្រឹងការគ្រប់គ្រង នៃការស្នើសុំគ្រឿងឥស្សរិយយស មេដាយស្ថាបនាជាតិ និងគោរម្យងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តលើកសំណើគោរពជូនថ្នាក់ដឹកនាំក្រសួងករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តព្រៃវែង កំពង់ចាម បន្ទាយមានជ័យ សៀមរាប និងខេត្តត្បូងឃ្មុំ។

**៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

-ប្រជុំពិនិត្យ និងកែសម្រួលសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងនីរន្តរភាព

-សិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្ដីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់។

**៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

- បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគ និងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ឃុំ សង្កាត់
- បន្តតាមដាន ត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់
- ពិនិត្យ ស្រាវជ្រាវស្វែងយល់លើនីតិវិធីលទ្ធកម្មក្រុង ស្រុក និងបញ្ហាប្រឈម ឬភាពរាំងស្ទះក្នុងការអនុវត្តគម្រោងក្រុង ស្រុក
- ផ្សព្វផ្សាយដល់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត អំពីសៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានកែសម្រួលរួច
- តាមដានការបិទបញ្ជីថវិការបស់ក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៧
- ត្រៀមធ្វើការវិភាជន៍ធនធានមូលនិធិឃុំ សង្កាត់ប្រចាំឆ្នាំ២០១៨
- ធ្វើការកែសម្រួលស្ដីពីការទទួលខុសត្រូវ តួនាទី ភារកិច្ច របស់មន្ត្រីក្នុងការិយាល័យ
- ពិនិត្យនីត្យានុកូលភាពលើរបាយការណ៍ដែលរដ្ឋបាលខេត្តផ្ញើមកដោះស្រាយពាក្យបណ្ដឹងនានា ព្រមទាំងការងារចំពោះមុខ
- ចុះសិក្សាស្រាវជ្រាវ បញ្ហាប្រឈម និងពិនិត្យកែសម្រួលឡើងវិញពីតួនាទីភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

**៤.៦-ការផ្ដល់សេវានៅថ្នាក់ក្រោមជាតិ**

-ប្រមូលនិងចងក្រងកិច្ចសន្យាគ្រប់គ្រងសំរាម និងកិច្ចសន្យាអនុវត្តកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានរបស់ក្រុងចំនួន១០គោលដៅដែលនៅសល់

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។

-បន្តចុះសិក្សាអំពីលទ្ធភាពនៃការពង្រីកការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋទៅស្រុកគោលដៅមួយចំនួនបន្ថែមទៀតក្នុងឆ្នាំ២០១៩

-បន្តរៀបចំសេចក្ដីព្រាងសេចក្ដីណែនាំស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយនៅថ្នាក់ស្រុកនិងឃុំ សង្កាត់

-បន្តតាមដាន ការសាងសង់អគារ ការិយាល័យច្រកចេញចូលតែមួយ សម្រាប់ស្រុកសង្កែ ស្រុកថ្មគោល និងស្រុកស្វាយអន្ទរ

-រៀបចំគំនូសប្លង់អគារសម្រាប់ផ្ដល់សេវា និងបញ្ជីសម្ភារបរិក្ខារ គ្រឿងសង្ហារឹម នៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-តាមដានគាំទ្រការបង្កើត និងដំណើរការអង្គភាពច្រកចេញចូលតែមួយ យន្តការច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ។

-បន្តគាំទ្រ និងតាមដានដំណើរការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-បន្តពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-បន្តពិនិត្យ និងកែសម្រួល លើសេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធី នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-បន្តពិនិត្យកែសម្រួលសេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

-បន្តពិនិត្យ និងលើកយោបល់ករណីសំណើសុំអញ្ជើញតំណាងរដ្ឋបាលខេត្តសៀមរាបចូលរួមជាសមាជិកនៃក្រុមការងារអន្តរក្រសួង ចំពោះកិច្ចសម្រាប់ត្រួតពិនិត្យឯកសារ និងបញ្ជីស្នាមពាក់ព័ន្ធ របស់ក្រុមហ៊ុន Mansudae Newtech Corporation Ltd. របស់កូរ៉េខាងជើង

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំការអនុញ្ញាតអញ្ជើញអភិបាលរាជធានី ខេត្តទាំង២៥រូបចូលរួមក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៨ លើប្រធានបទ "វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ឧស្សាហូបនីយកម្ម កំណើន សេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា"

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំកិច្ចសហការ និងសម្របសម្រួលពីស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការសិក្សាអង្កេតរូបភូគព្ភសាស្ត្រ និងបច្ចេកទេសភូគព្ភសាស្ត្ររបស់ក្រុមហ៊ុន Kris Energyនៅប្លុកA ដែនសមុទ្រកម្ពុជា

- បន្តសហការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីចូលរួមជាសមាជិកក្រុមការងារវាយតម្លៃអញ្ញមញ្ញស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម និងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់(APG)។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន**

-បន្តធ្វើការបូកសរុប និងសិក្សាលើកយោបល់ ពាក់ព័ន្ធនឹងសកម្មភាពទូទៅរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនក្នុងបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តស្វាយរៀងស្នើសុំបង្កើតច្រកទ្វារតំបន់ព្រំដែនក្រសាំងជ្រំស្ថិតក្នុងភូមិក្រសាំងជ្រំ ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីបង្កើត និងតម្លើងកម្រិតច្រកទ្វារព្រំដែនក្នុងបណ្តាខេត្តជាប់ព្រំដែនវៀតណាម

-បន្តសម្របសម្រួលកិច្ចការនានា ដើម្បីរៀបចំការសាងសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធ និងរៀបចំសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-បន្តពិនិត្យ និងលើកយោបល់ករណីភាគីវៀតណាមស្នើសុំសាងសង់ស្លានបេតុងសសរដែកថែប នៅច្រកទ្វារតំបន់ព្រំដែនហ្វាហៀប(ខេត្តតាកែវ) ទល់មុខនឹងច្រកទ្វារតំបន់ព្រំដែនខ្សែដែក(ខេត្តស្វាយរៀង)។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តធ្វើការសិក្សា និងលើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនឹងការចងសម្ព័ន្ធមេត្រីភាព រវាងបណ្តារាជធានី ខេត្ត និងក្រុង នៃព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តារាជធានី ខេត្ត និងក្រុងរបស់ប្រទេសជាមិត្ត

-បន្តធ្វើការស្នើសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល ករណីរដ្ឋបាលខេត្តព្រះសីហនុស្នើសុំចងសម្ព័ន្ធមេត្រីភាពជាមួយក្រុងចំនួន ០៤ នៃសាធារណរដ្ឋប្រជាមានិតចិនរួមមាន៖ ទីក្រុង**លីស្វយនីង** នៃខេត្តស៊ីឈ័ន ទីក្រុង**កានចូវ** នៃខេត្តជាំងស៊ី ទីក្រុង**នីងប៉ូ** នៃខេត្តជឺជាំង និងខេត្តគួយចូវ

-បន្តធ្វើការស្នើសុំគោលការណ៍អនុញ្ញាត ករណីរដ្ឋបាលខេត្តត្បូងឃ្មុំ ស្នើសុំចងសម្ព័ន្ធមេត្រីភាពជាមួយគណៈកម្មាធិការប្រជាជនខេត្តតៃនិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

### ៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

- បន្តពិនិត្យ និងលើកយោបល់ករណីសំណើសុំធ្វើវិនិយោគតំបន់រមណីយដ្ឋាន "បឹងយក្សឡោម" មានទំហំ**២៨០**ហិកតា ផ្ទៃបឹងសរុប **៥០.២៤**ហិកតា

-បន្តពិនិត្យ និងលើកយោបល់ ករណីសំណើសុំជួលរយៈពេលវែងទីតាំងដីស្ថិតនៅឃុំកំពង់ស្រឡៅពីរ ស្រុកឆែប ខេត្តព្រះវិហារ ដែលមានទំហំ **១០៣,៩៨**ហិកតា

-បន្តពិនិត្យ និងលើកយោបល់ ករណីសុំអន្តរាគមន៍ពីសម្តេចក្រឡាហោម និងរដ្ឋបាលរាជធានីភ្នំពេញដើម្បីពិនិត្យ និងអនុញ្ញាតជាគោលការណ៍ឱ្យក្រុមហ៊ុនហ្វ្រីនខេមបូឌាប្រធីធី អ៊ិនវេសមិន ឯ.ក បានធ្វើអភិវឌ្ឍលើទីតាំងដីបឹងទំពុនដែលមានទំហំ**៤៧**ហិកតា ស្ថិតនៅភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

### ៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- បន្តពិនិត្យ និងលើកយោបល់ អំពីការស្នើសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃរចនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការលុបឈ្មោះ ការផ្អាកសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

- បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបនូវរបាយការណ៍ស្តីពីសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- បន្តពិនិត្យ និងប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- បញ្ចូលទិន្នន័យ ស្កេនសំណុំឯកសាររបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- បន្តចូលរួមជាមួយក្រុមការងារគណៈកម្មការមូលប័ត្រកម្ពុជាក្នុងការផ្សព្វផ្សាយ និងការស្វែងយល់អំពីការជួញដូរមូលប័ត្រនៅកម្ពុជា និងសហការជាមួយអាជ្ញាធររាជធានី ខេត្ត ដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មលើគម្រោងវិនិយោគរួមគ្នាដោយគ្មានអាជ្ញាប័ណ្ណ

-បន្តចូលរួមជាសមាជិកក្រុមការងារវាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិច ស្តីពីការសម្អាតប្រាក់ (APG)

-បន្តបូកសរុបរបាយការណ៍ស្តីពីការបំពេញកាតព្វរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលតាមលិខិតជូនដំណឹងស្តីពីការរំលឹកចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលខកខានមិនបានបំពេញកាតព្វកិច្ចតាមការកំណត់ដោយច្បាប់។

#### ៦.៤.២-ការងារគណបក្សនយោបាយ

-បន្តតាមដានប្រមូលព័ត៌មានពីគ្រប់បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមពាក់ព័ន្ធនឹងគណបក្សនយោបាយ

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត ចុះបញ្ជី និងលុបឈ្មោះ

- រៀបចំលិខិតឆ្លើយតបទៅគណបក្សសិទ្ធិមនុស្សពាក់ព័ន្ធនឹងការសុំរំលាយគណបក្ស

-ពិនិត្យ រៀបចំឯកសារពាក់ព័ន្ធស្នើសុំប្តឹងទៅតុលាការកំពូល ដើម្បីរំលាយគណបក្សនយោបាយចំនួន ០៣

-រៀបចំបូកសរុបរបាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់គណបក្សនយោបាយឆ្នាំ២០១៧

-រៀបចំសេចក្តីជូនដំណឹងទៅរដ្ឋបាលរាជធានី ខេត្ត ស្តីពីការបង្កលក្ខណៈឱ្យគណបក្សនយោបាយធ្វើសកម្មភាពចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលនឹងប្រព្រឹត្តទៅ នៅខែកក្កដា ឆ្នាំ២០១៨ ខាងមុខ៕

**អគ្គនាយក** ស្ត.

ប្រាក់ សំអឿន

__ចម្លងជូន៖__

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្តីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-អគ្គនាយកដ្ឋានអន្តោប្រវេសន៍*
*-អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម*
*-ក្រុមប្រឹក្សានីតិកម្ម*
*-បណ្ឌិត្យសភានគរបាលកម្ពុជា*
*-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*